MN DEPARTMENT OF HEALTH

# ប្រភពព័ត៌មានដើម្បីស្វែងរកសេវាកម្មថែទាំសុខភាព ឬទទួលបានសេវាកម្មធានារ៉ាប់រងសុខភាពក្នុងតម្លៃទាប

## ស្វែងរកសេវាកម្មថែទាំសុខភាពដែលមានតម្លៃទាប

- **កម្មវិធីស្ពានសម្រាប់អត្ថប្រយោជន៍ (Bridge to Benefits) ៖ កម្រងព័ត៌មានសេវាកម្មថែទាំសុខភាពក្នុងតម្លៃទាបនៅរដ្ឋមីណេសូតា**
  (www.bridgetobenefits.org/MN_Low_Cost_Health_Care_Directory)
  សូមវាយបញ្ចូលឈ្មោះខោនធីរបស់អ្នកដើម្បីស្វែងរកបញ្ជីរគ្លីនិកថែទាំសុខភាពក្នុងតម្លៃទាប ដែលនៅជិតអ្នក ។

- **សមាគមន៍រដ្ឋមីណេសូតានៃមជ្ឈមណ្ឌលសុខភាពសហគមន៍ (MNACHC, Minnesota Association of Community Health Centers)**
  (https://mnachc.org/community-health-centers/find-a-health-center/)
  សូមប្រើផែនទី ឬវាយបញ្ចូលឈ្មោះទីកន្លែងរបស់អ្នក ដើម្បីរកមើលមជ្ឈមណ្ឌលសុខភាពសហគមន៍ (មជ្ឈមណ្ឌលសុខភាពដែលទទួលស្គាល់ដោយសហព័ន្ធ) ដែលនៅជិតអ្នក ។ មជ្ឈមណ្ឌលសុខភាពសហគមន៍ មានផ្តល់ជូនសេវាកម្មវេជ្ជសាស្រ្ត ទន្តសាស្រ្ត និងសុខភាពផ្លូវចិត្ត ចំពោះពលរដ្ឋដែលពិបាកទទួលបានសេវាកម្មទាំងអស់នេះ ។

## ស្វែងរកការធានារ៉ាប់រងសុខភាព

- **ដាក់ពាក្យ និងចុះឈ្មោះជាសមាជិកធានារ៉ាប់រងសុខភាព MNsure**
  (www.mnsure.org/new-customers/apply/index.jsp)
  អ្នកអាចដាក់ពាក្យធានារ៉ាប់រងសុខភាព ដូចជាជំនួយវេជ្ជសាស្រ្ត (Medical Assistance) និងសេវាកម្មថែទាំសុខភាពមីណេសូតា (MinnesotaCare) តាមអនឡាញ ឬស្វែងរកជំនួយពីអ្នកជំនាញក្នុងការចុះឈ្មោះចូលជាសមាជិក ឲ្យជួយអ្នក ។ អ្នករស់នៅក្នុងរដ្ឋមីណេសូតា ភាគច្រើនដែលបានចុះឈ្មោះ តាម  រយៈកម្មវិធី MNsure មានលក្ខណៈសម្បត្តិអាចទទួលបានជំនួយហិរញ្ញវត្ថុ ។

- **អ្នកជួយណែនាំអំពី កម្មវិធីធានារ៉ាប់រងសុខភាព MNsure**
  (https://www.mnsure.org/help/find-assister/find-navigator.jsp)
  អ្នកជួយណែនាំ អាចជួយអ្នកចុះឈ្មោះចូលកម្មវិធី Medical Assistance ឬ MinnesotaCare (បើអ្នកមានសិទ្ធិទទួលបានជំនួយទាំងអស់នេះ) ។ ពួកគេ ក៏អាចជួយអ្នកឲ្យចុះឈ្មោះក្នុងផែនការធានារ៉ាប់រងសុខភាពដោយក្រុមហ៊ុនឯកជន ព្រមទាំងផ្តល់ការអប់រំអំពីមូលដ្ឋានគ្រឹះនៃការថែទាំសុខភាព ដល់អ្នកផង   ដែរ ។ អ្នកជួយណែនាំភាគច្រើន មានទីកន្លែងធ្វើការនៅក្នុងអង្គការសហគមន៍ ដើម្បីផ្តល់ជំនួយដោយប្រើភាសាចិន សូម៉ាលី អេស្ប៉ាញ មន និងវៀតណាម ។

- **កម្មវិធីប្រមាណភាពមានសិទ្ធិទទួលបានការធានារ៉ាប់រងលើថ្លៃសម្រាកពេទ្យ (Hospital Presumptive Eligibility Program)**
  (https://mn.gov/dhs/partners-and-providers/policies-procedures/minnesota-health-care-programs/provider/hpe/)
  អ្នកអាចចុះឈ្មោះស្នើសុំជំនួយពីកម្មវិធី Medical Assistance ឬ MinnesotaCare នៅពេលអ្នកសម្រាកពេទ្យ ។ បើអ្នកស្ថិតក្នុងលក្ខណៈវិនិច្ឆ័យត្រូវទទួលបានជំនួយ គឺអ្នកអាចទទួលបានការធានារ៉ាប់រងថ្លៃ សេវាកម្ម នៅមុនពេលអ្នកត្រូវបំពេញពាក្យសុំឲ្យបានពេញលេញ ។

## ស្វែងរកសេវាកម្មថែទាំសុខភាពបន្ថែម

- **នាយកដ្ឋានសុខាភិបាលប្រចាំមូលដ្ឋាន និងក្រុមប្រឹក្សាសុខភាពសហគមន៍**
  (https://www.health.state.mn.us/communities/practice/connect/findlph.html)
  សូមទាក់ទងជាមួយនឹងនាយកដ្ឋានសុខាភិបាលប្រចាំមូលដ្ឋាន និង/ឬក្រុមប្រឹក្សាសុខភាពសហគមន៍ នៅតាមខោនធីរបស់អ្នក ដើម្បីស្វែងរកគោការណ៍ណែនាំ និងសួរនាំអំពីសេវាកម្មនានាដែលអ្នកអាចមានសិទ្ធិទទួលបាន ។

Minnesota Department of Health
625 Robert St. N., PO Box 64975
St. Paul, MN 55164-0975
651-201-5414
www.health.state.mn.us

02/13/2020

*ដើម្បីទទួលបានព័ត៌មាននេះ ក្នុងទ្រង់ទ្រាយផ្សេង សូមហៅទូរស័ព្ទមកលេខ ៖651-201-5414*